# ជ្រុលក្បាលក្រពើ

ដោយ អាំង ជូលាន

ខ្មែរទាំងអស់គ្នា ឬក៏បរទេសណាដែលចេះខ្មែរជ្រៅជ្រះ តែងតែស្គាល់ពាក្យថា "ជ្រុលក្បាលក្រពើ" ដែលមានន័យថា អំពើអ្វីមួយធ្វើជ្រុលទៅហើយពុំអាចដកថយក្រោយមកវិញបាន។ ពាក្យពេចន៍នេះប្រើញឹកញាប់ណាស់ ប៉ុន្តែជាទូទៅអ្នកនិយាយឬអ្នកស្តាប់ពួននោះ ប្រហែលតែយល់ តែពុំសូវគិតថាហេតុអ្វីបានជាថាដូច្នោះឡើយ។ តើក្បាលក្រពើនៅក្នុងពាក្យនេះមានទាក់អ្វីដែរនៅក្នុងគំនិតដែលថាជ្រុលថយក្រោយវិញមិនកើត?

ពាក្យនេះទាល់តែស្គាល់រទេះគោឬក្របីច្បាស់ទើបយល់។ រទេះដែលមានរូបរាងពេញលេញប្រាកដ តែងមានចន្ទោល។ ចន្ទោលនោះគឺជាផ្នែកដែលតចេញពីទូករទេះទៅត្រង់ចំណុចដែលភ្ជាប់នឹម ប្រហែលតែដូនកាលគេដោះចេញក៏ដោយ។ ក្រៅអំពីសម្រាប់ស្មានដំណើរបស់បែបនៃរទេះ តួនាទីផ្នែកសោភ័ណភាពនៃចន្ទោលនោះសំខាន់ណាស់ ( រូបលេខ១_៣)។


រូបលេខ១


រូបលេខ២


រូបលេខ៣

បើរទេះនោះគេដោះចន្ទោលចេញ (រូបលេខ៤) ហើយយើងពិនិត្យចុងទូកនៅក្រោមនឹមនោះ យើងនឹងឃើញថាខាងចុងគេចាំងធ្លាក់ឱ្យមានរូបរាងដូចក្បាលក្រពើដូច្នោះមែន (រូបលេខ៥_៨)។ បើដោះនឹមនោះចេញទៅទៀត គឺក្បាលក្រពើទាំងមូលនោះកាន់តែចេញឱ្យឃើញច្បាស់ (រូបលេខ៩)។


រូបលេខ៤


រូបលេខ៥


រូបលេខ៦



រូបលេខ១៧



រូបលេខ១៨



រូបលេខ១៩

យើងដឹងហើយថាពាហនៈគោឬក្របីមិនចេះដើរថយក្រោយទេ។ នៅពេលដែលរទេះបរទៅក្នុងព្រៃតាមច្រកចង្អៀតតូចៗ ឬពុំនោះទេ តាមផ្លូវរទេះធម្មតាដែលព្រៃឬរុក្ខជាតិអមកៀកជាប់ គឺត្រូវតែទៅមុខរហូត បើចង់ថយមកក្រោយទាល់តែទៅដល់ទីលំហណាមួយសិន ដើម្បីបត់រទេះ។ ដូច្នេះ បើចំណុចក្បាលក្រពើនៃរទេះនោះចាប់ផ្តើមចូលទៅដល់ច្រកណាមួយចង្អៀតហើយ បានសេចក្តីថាចន្ទោលរុលទៅមុខនោះឆ្ងាយរួចហើយ ដូច្នោះពុំអាចងាករេមកក្រោយវិញបានឡើយ។ នេះហើយដែលគេហៅថា "ផ្តុលក្បាលក្រពើ"។